ខ្លឹមសារសង្ខេប

# កម្ពុជា

## កំណើនសេដ្ឋកិច្ចដ៏លឿន ក្នុងបរិយាកាសដែលមានការប្រឈម



មករា ២០០៩

*សំគាល់: នេះគឺជាឯកសារពង្រាងនៃខ្លឹមសារសង្ខេបសំរាប់ពិគ្រោះយោបល់ ។ ឯកសារទាំងមូល អាចរកបានតាមវេបសាយ www.worldbank.org/kh/growth ។ របាយការណ៍ទាំងមូលនឹងបោះពុម្ពបន្ទាប់ពីការពិគ្រោះយោបល់នេះ ។*

*Note: the findings, interpretations, and conclusions expressed in this document are entirely those of the author(s) and are not necessarily of the World Bank, or its affiliated organizations, or members of its Board of Executive Directors or the countries they represents. The World Bank does not guarantee the accuracy of the data included in this document and accepts no responsibility whatsoever for any consequence of their use.*

# ការធានាកំណើនសេដ្ឋកិច្ចក្នុងបរិយាកាសដែលមានការប្រួលប្រួល

## ខ្លឹមសារសង្ខេប

១. ប្រទេសជាច្រើន ទទួលជោគជ័យក្នុងការធានាអោយមានកំណើនសេដ្ឋកិច្ចខ្ពស់នៅក្នុងដំណាក់កាលមួយចំនួន ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ប៉ុន្តែមានតែប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដែលអាចធ្វើអោយកំណើនមានសន្ទុះលឿន និងមាននិរន្តរភាពសំរាប់អំឡុងវែងបាន។ មានតែការបន្លាយ អំឡុងពេលកំណើនសេដ្ឋកិច្ចបែបនោះទេ ទើបអាចធ្វើអោយមានផលវិជ្ជមានធំធេងលើប្រាក់ចំណូលរបស់ប្រជាជនម្នាក់ៗ។ ហើយផលវិជ្ជមានធំធេងនោះ តែងតែនាំអោយមានលទ្ធផលសំខាន់ៗ ជាច្រើនទៀត ដែលប្រជាពលរដ្ឋ យកចិត្តទុកដាក់។

២. កម្ពុជាគឺជា ប្រទេសមួយក្នុងចំណោមប្រទេសក្នុងក្រុមប្រទេសពិសេសទាំងនោះ។ ប្រទេសកម្ពុជាទទួលបានកំណើនប្រាក់ចំណូល ក្នុងបុគ្គលម្នាក់ៗច្រើនជាងទ្វេគុណក្នុងទសវត្សដែលកន្លងទៅនេះពីចំនួន ២៨៥ ដុល្លាក្នុងម្នាក់ ក្នុងមួយឆ្នាំ នៅឆ្នាំ ១៩៩៧ ទៅដល់ ៥៩៣ ដុល្លាក្នុងឆ្នាំ ២០០៧ ។ កំណើននេះកើតឡើងដោយសារ ការផ្លាស់ប្តូរ និង កំណែទម្រង់រចនាសម្ព័ន្ធដ៏ជ្រាលជ្រៅ ដូចជាៈ

ការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកល, ការប្តូរការងារពី កសិកម្ម ទៅជាផលិតកម្ម, អន្តរកាលប្រជាសាស្ត្រ, និង ចលនាប្រជាជនពីជនបទ ចូលមកទីប្រជុំជន។ លទ្ធផលទាំងនេះ ប្រែក្លាយកំណើនអោយទៅជាការងារ និងសេវាកម្មល្អ និងបានចូលរួមកាត់បន្ថយភាពក្រីក្រ កែលំអវិស័យសុខភាព និង ការអប់រំបានយ៉ាងច្រើនទៀតផង។

៣. ទោះបីជាបែបនេះក្តី ដំណើររីកចំរើននៃរឿងល្អមិនប្រាកដនិយមទេ។ សមិទ្ធិផលក្នុងទសវត្សកន្លងទៅមានភាពផុយស្រួយ និងបន្សល់ទុកភាពក្រីក្រ និងធនធានតិចតួចសំរាប់ប្រជាជនកម្ពុជាមួយចំនួនធំផងដែរ។ មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចនេះ ទំនងជាតូចចង្អៀតនៅឡើយ។ ហើយចរន្ត ដែលបានជួយកម្ពុជាយ៉ាងល្អនោះរួមមានលំហូរពាណិជ្ជកម្មសកល និង លំហូរ វិនិយោគ យ៉ាងហោចណាស់ បានបាត់បង់ថាមពលជាបណ្តោះអាសន្នដែរ។

៤. តើកម្ពុជាត្រូវប្រកាន់យកវិធានការអ្វីដើម្បីបន្តនូវកំណើននេះ ដើម្បីក្លាយទៅជាប្រទេស ដែលមានចំណូលមធ្យមក្នុងមួយទសវត្ស ឬលើសពីនេះ និងលើកស្ទួយប្រជាជនរបស់ខ្លួន អោយរួចផុតពីភាពក្រីក្រ?

របាយការណ៍នេះ មានគោលបំណងផ្តល់ជូនអ្នកធ្វើនយោបាយ និងការត្រិះរិះពិចារណារបស់ប្រជាជនកម្ពុជា អំពីកំណើនសេដ្ឋកិច្ចនៅកម្ពុជា តាមមធ្យោបាយបីយ៉ាង ដូចតទៅៈ (១) របាយការណ៍នេះ ពិនិត្យឡើងវិញនូវបទពិសោធន៍ ក្នុងទសវត្សកន្លងទៅ និងទាញយកមេរៀនជាក់លាក់របស់កម្ពុជា ក្នុងអំឡុងពេលមានកំណើនសេដ្ឋកិច្ចដ៏លឿននោះ។ (២) របាយការណ៍នេះ គូសបញ្ជាក់អំពីប្រភពកំណើនសេដ្ឋកិច្ច ដែលមានសក្តានុពល និងមានគោលបំណងវាយតម្លៃរបាំងដែលរារាំងកំណើនសេដ្ឋកិច្ចនេះ និង (៣) របាយការណ៍នេះ គូសបញ្ជាក់ពី ជម្រើស គោលនយោបាយ ដើម្បីដោះស្រាយបញ្ហា របាំទាំងនោះ។

**៥.** ការវិភាគ មានសារៈសំខាន់ៗចំនួនបី។ ទី១. កំណើនសេដ្ឋកិច្ច ក្នុងទសវត្សកន្លងទៅនេះ គឺជាសមិទ្ធិផលគួរអោយកត់សំគាល់មួយ។ ប៉ុន្តែកំណើននេះទំនងជាគ្មាននិរន្តរភាពទេ។ អំណាចនេះសបញ្ជាក់ថា យើងមានភស្តុតាងច្បាស់ថា វិធានការនយោបាយល្អ និងអភិបាលកិច្ចល្អ នៅក្នុងវិស័យខ្លះ នាំអោយមានកំណើនសេដ្ឋកិច្ច។

**ទី២.** កម្ពុជាមានសក្តានុពលក្នុងការធ្វើអោយកំណើនសេដ្ឋកិច្ចមាននិរន្តភាព ប្រសិនបើកំណើននោះ រីកសាយក្នុងវិស័យផ្សេងៗទៀត។ ដើម្បីធ្វើបែបនេះបាន យើងត្រូវមានយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចច្បាស់លាស់មួយ។ ទីបំផុតកាលានុវត្តភាពបី មានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ដូចជាការតម្រែតម្រង់សមាហរណកម្ម ក្នុងតំបន់សំរាប់កំណើនសេដ្ឋកិច្ច ការគ្រប់គ្រងធនធានធម្មជាតិ តាមមធ្យោបាយដែលមាននិរន្តភាព និងការវិនិយោគសំរាប់អនាគតរបស់ខ្លួន (តាមរយៈ វិសយ័កសិកម្ម ហេដ្ឋារចនាសម្ពន្ធ័ ការអប់រំ និង ការសន្សំសំចៃខ្ពស់)។

**៦.** ការវិភាគនេះ ផ្អែកលើការអភិវឌ្ឍថ្មីៗ ទាក់ទង និង ការគិតគូរអំពីកំណើនសេដ្ឋកិច្ច ជាពិសេស របាយការណ៍របស់គណកម្មាការកំណើនសេដ្ឋកិច្ចឆ្នាំ ២០០៨ ។ យើងប្រើរបាយការណ៍នេះដើម្បីអនុវត្តការតាមដានរកអោយឃើញថា វិធីសាស្ត្រនេះ អ្វីបានផល និង អ្វីដែលមិនបានផលក្នុងបរិបទប្រទេសកម្ពុជា ដើម្បីលើកសំណើសិក្សាវិភាគលើឧបសគ្គសំខាន់ៗដែលរារាំងកំណើនសេដ្ឋកិច្ច និងមានការជ្រើរើសយកសកម្មភាពទាំងឡាយណា ដែលនឹងនាំមកនូវកំណើនសេដ្ឋកិច្ចច្បាស់ជាងគេបំផុត ។ ជាដំបូងយើងទទួលស្គាល់ថាយើងមិនទាន់ដឹងអ្វីច្រើនអំពីដំណើរការនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍទេ។ ដូច្នេះ យើងមានទស្សនៈថា ការពិសោធន៍ ការតាមដាន និង ការវាយតម្លៃ គឺជាកត្តាដ៏សំខាន់នៃយុទ្ធសាស្ត្រដែលជោគជ័យ។

## ការយល់ដឹងពីកំណើនសេដ្ឋកិច្ចឆាប់រហ័សក្នុង១ទសវត្ស

**៧.** លក្ខណៈពិសេសបួនយ៉ាង នៃកំណើនសេដ្ឋកិច្ច ឆាប់រហ័ស ក្នុងទសវត្សនេះ គឺជាកត្តាសំខាន់ណាស់ (ជំពូកទី១)។ **ទី១** ពីឆ្នាំ ១៩៩៧ ដល់ ឆ្នាំ ២០០៧ កំណើនសេដ្ឋកិច្ច ត្រូវបានបង្កើតឡើង ដោយសេដ្ឋកិច្ចបើកចំហ និងបរិយាកាសម៉ាក្រូសេដ្ឋកិច្ចដែលមាននិរន្តរភាព។ ទាំងអស់នេះ ជាលក្ខណៈពិសេសម៉ាក្រូសេដ្ឋកិច្ចដែលអាចមើលឃើញក្នុងកំណើនឆាប់រហ័ស ក្នុងការនាំចេញ និង វិនិយោគបរទេសផ្ទាល់ និងស្ថេរភាពអតិជនណា (ក្នុងអត្រាមធ្យម ៤.៧ ភាគរយ ក្នុងទស្សវត្សកន្លងមក) និងអត្រាប្តូរប្រាក់។ **ទី២** ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដែលមាន ស្ថេរភាពត្រូវបានសម្រេចដល់គោលដៅ ដោយមានលិខិតុបករណ៍គោលនយោបាយគាំទ្រមួយចំនួនតូច។ តាមពិតសេដ្ឋកិច្ចត្រូវបានស្ថិតក្នុងដុល្លារូបនិយកម្មមួយផ្នែកធំ ហើយទុកអោយនយោបាយរូបិយប័ណ្ណស្ថិតនៅក្នុងនយោបាយច្របូកច្របល់ និង បង្កើតភាពងាយរងគ្រោះ។ **ទី៣** កំណើនសេដ្ឋកិច្ចមានមូលដ្ឋានតូចចង្អៀត។ វិស័យនាំមុខបួនធំៗរួមមាន វិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យសំណង់ និងវិស័យកសិកម្ម។ មានការពង្រីកផលិតភាពតិចតួចណាស់ក្រៅពីវិស័យទាំងនេះ។ ផលិតផលវិស័យកាត់ដេរ មានចំណែក៨៨ភាគរយ ក្នុងការនាំចេញសរុប។ ចំណុចនេះបានបន្ថែមស្រទាប់ដែលមាន ភាពងាយរងគ្រោះមួយទៀតទៅលើសមិទ្ធិផល កំណើនសេដ្ឋកិច្ច។ **ទី៤.** កំរិតនៃប្រាក់សន្សំ និងវិនិយោគក្នុងស្រុក នៅមានកំរិតទាប (គឺ ១៣ និង ១៤ ភាគរយនៃ GDP ជាបន្តបន្ទាប់) ទោះបីជាវាកំពុង

បន្តកើនឡើងក្តី។ នៅពេលដែលលក្ខខណ្ឌនេះ ជាកត្តាំពឹងទុក និងជាលក្ខខណ្ឌចាប់ផ្តើមរបស់កម្ពុជាក្នុងទសវត្ស ឆ្នាំ១៩៩០ក្តី ក៏វាមានការខុសគ្នាពីបទពិសោធន៍ នៃកំណើនសេដ្ឋកិច្ចឆាប់រហ័ស ជាពិសេស នៅអាស៊ីខាងកើត។ ប្រការពាក់ពន្ធ័ នឹងចំណុចនេះគឺការអភិវឌ្ឍន៏ថ្មីៗ និង ឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុដែលផ្តើមចេញពីមូលដ្ឋានទាបមួយ ដែលជាហិរញ្ញប្បទាន ដែលគេត្រូវការជាចាំបាច់ ប៉ុន្តែវាក៏មានហានិភ័យផងដែរ។

**៨- តើបញ្ហានេះកើតឡើង តាមរបៀបណា?**

មានកត្តាសំខាន់ៗចំនួនបីដែលជួយពន្យល់អំពីកម្លាំងចលករនៃការរីកចំរើនដ៏ឆាប់រហ័សនេះ (ជំពូកទី២)។ វាមិនមែនជាកត្តាបំពេញគ្នាទៅវិញទៅមកតែមួយមុខទេ ហើយចំណុចនីមួយៗ ផ្តល់នូវការយល់ដឹងដ៏មានប្រយោជន៍ សំរាប់ ពេលអនាគត (តារាងទី១)៖

- កម្ពុជាបានទទួលផលប្រយោជន៍ពីប្រវត្តិសាស្ត្រថ្មីៗ របស់ខ្លួន ពោលគឺការបញ្ចប់ជម្លោះ និង ការបង្កើតស្ថេរភាពនយោបាយ កំណើនដ៏ឆាប់រហ័សនៃពាណិជ្ជកម្មពិភពលោក និង អន្តរកាលប្រជាសាស្ត្រ និង ទីតាំងភូមិសាស្ត្រដែលអំណោយផលរបស់ខ្លួន។ កម្ពុជា ជាប្រទេសជាប់មាត់សមុទ្រ ស្ថិតនៅចំចំណុចកណ្តាលអាស៊ីអាគ្នេយ៍។ តាមទស្សនៈ ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រនេះ សមិទ្ធិផលដែលទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ដែលមាននិរន្តភាព គឺស្ថេរភាពនយោបាយ និង ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសនេះ និង គោលនយោបាយទាំងអស់ដែលបានអនុញ្ញាតអោយប្រទេសនេះធ្វើសមាហរណកម្មនៅក្នុងតំបន់។ កត្តាទាំងនេះ ផ្តល់លទ្ធភាពអោយប្រទេសបង្កើត កំណត់ត្រាតាមដានការប្រែប្រួលរាប់បញ្ចូលទាំង ការចូលជាសមាជិក អង្គការ ពាណិជ្ជកម្ម ពិភពលោក និង អនុមត័ច្បាប់សេដ្ឋកិច្ចសំខាន់ៗមួយចំនួន។

**តារាងទី១: ការយល់ដឹងអំពីកំណើនសេដ្ឋកិច្ចឆាប់រហ័សមួយទសវត្ស**

| កត្តានានា | | ភស្តុតាង | មេរៀនទទួលបាន |
|---|---|---|---|
| ១.ប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ | ផលប្រយោជន៍ពីប្រវត្តិសាស្ត្រ (ក្រោយសង្គ្រាម, កំណើនសេដ្ឋកិច្ចសកលលោក, អន្តរកាលប្រជាសាស្ត្រ)និង ភូមិសាស្ត្រ(អាស៊ីខាងកើត) | ពេលវេលានៃកំណើននិងកំណើនពាណិជ្ជកម្ម និង វិនិយោគ បរទេសផ្ទាល់ និន្នាការប្រជាសាស្ត្រ (អត្រាពឹងផ្អែក) | តួនាទីនៃស្ថេរភាព នយោបាយ និង ម៉ាក្រូសេដ្ឋកិច្ច តួនាទីនៃការបើកចំហរ និង ការប្តេជ្ញាអន្តរជាតិ |
| ២.ការប្រើទ្រព្យសកម្មគ្មាននិរន្តរភាព | កំណើនកើតឡើងដោយសារការប្រើធនធានធម្មជាតិតែម្តង | ការប្រើប្រាស់ច្រើន ប្រាក់សន្សំតិច មានអសមភាព ចំណូលខ្ពស់ពីទ្រព្យខ្លះ ការគ្រប់គ្រងធនធានធម្មជាតិ | ត្រូវមានការគ្រប់គ្រង ធនធានធម្មជាតិ ដែលមាននិរន្តរភាព ត្រូវបង្កើនប្រាក់ |

| | | | |
|---|---|---|---|
| ៣.អភិបាលកិច្ចតាមវិស័យ ជាក់លាក់ | កំណើនតាមរយៈដំណោះស្រាយសង្កត់ធ្ងន់ តូចចង្អៀតចំពោះ អភិបាលកិច្ចមិនល្អជាទូទៅ | គ្មាន និរន្តរភាព<br><br>វិស័យកាត់ដេរជោគជ័យ (ការបន្តកូតា, តាមដានដោយកម្មវិធីរោងចក្រកាន់តែប្រសើរ នៅកម្ពុជា, សមត្ថភាពសមាគមនី អាជីវកម្ម និងទំនាក់ទំនងជិតស្និត ជាមួយរដ្ឋាភិបាល) តួនាទីវេទិការដ្ឋាភិបាល និងវិស័យឯកជន | សន្សំក្នុងស្រុក និង/ឬ ប្រាក់សន្សំក្រៅប្រទេស<br><br>តួនាទីអ្នកតាមដានឯករាជ្យ (ស្តង់ដាពលកម្ម ក្នុងវិស័យកាត់ដេរ) កត្តាជំរុញខាងក្រៅ និងសូចនាករ តួនាទីសកម្មរបស់រដ្ឋាភិបាល ក្នុងការបង្កើតបរិយាកាសអាជីវកម្មល្អ |

- កម្ពុជាបានជួយជំរុញកំណើនសេដ្ឋកិច្ច ដោយប្រើប្រាស់ទ្រព្យមួយចំនួនរបស់ខ្លួន (ធនធានព្រៃឈើ, ធនធាន នេសាទ, ដីធ្លី, មណ្ឌលទេសចរណ៍ អង្គរវត្ត) ប៉ុន្តែការធ្វើបែបនេះ បានកាត់បន្ថយបរិមាណ ឬគុណភាពនៃ ទ្រព្យសម្បត្តិទាំងនោះ។ បញ្ហានេះបង្ហាញពីកង្វះខាតប្រាក់សន្សំទូទៅ និងការបែងចែកប្រាក់សន្សំមិនបានត្រឹមត្រូវ។ ភស្តុតាងបញ្ជាក់ពីគំនិតនេះ អាចស្តើងឡើងតាមរយៈកំរិតប្រាក់សន្សំក្នុងស្រុកទាប ទោះបីជាមានការកើនឡើងក៏ដោយទ្រព្យប្រភេទខ្លះមានផលរបរខ្ពស់ (ដូចជា អចលនទ្រព្យ, ដីធ្លី) កំណើននៃអសមភាព និង អាយុកាលខ្លីនៃការវិនិយោគទាំងឡាយ។ បញ្ហានេះបង្ហាញពីបែបបទនៃកំនើនសេដ្ឋកិច្ច ដែលគ្មាននិរន្តរភាព និងបញ្ជាក់ពីសារៈសំខាន់នៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលមាននិរន្តរភាព។
- កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចឆាប់រហ័ស ក្នុងបរិយាកាសអភិបាលកិច្ចមិនល្អ តាមរយៈចំណាត់ការវិស័យ ឬចំណាត់ការផលិតផលជាក់លាក់ ។ ការចរចារព្រមព្រៀងពាណិជ្ជកម្មសហរដ្ឋអាមេរិក កម្ពុជា បានធ្វើឡើង ក្នុងឆ្នាំ ១៩៩៩ បានផ្សារភ្ជាប់ការបង្កើនកូតាជាបន្តបន្ទាប់ ស្របតាមការកែលំអរស្តង់ដារពលកម្ម ផ្សារភ្ជាប់ទៅ អ្នកតាមដាន ដែលជាភាគីទី៣ គឺកម្មវិធីអង្គការពលកម្មអន្តរជាតិ ដែលមានឈ្មោះថា Better Factory Cambodia, BFC (កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា) ។ ប្រការនេះបានផ្តល់ជូនកម្ពុជានូវកេរ្តិ៍ឈ្មោះអន្តរជាតិអន្តរជាតិ សំរាប់ឧស្សាហកម្មទូទៅ ក្នុង ការសំរេចបានមនូវស្តង់ដារទាំងនេះ ជាពិសេសផ្តល់អត្ថប្រយោជន៍ប្រកួតប្រជែងសំរាប់ឧស្សាហកម្មទាំងមូល។ វិធានការរួមរបស់សហគមន៍ផលិតករកាត់ដេរកម្ពុជា ( GMAC ) មានសម្ព័ន្ធភាពយ៉ាងជិតស្និទ្ធជាមួយដៃគូរដ្ឋាភិបាល ជាពិសេសនៅក្នុងក្រសួងពាណិជ្ជកម្មដែលបន្តដោះស្រាយបញ្ហាប្រឈម ដើម្បីធានាកំនើនសេដ្ឋកិច្ចក្នុងវិស័យ (មួយចំណែកនៃការងារនេះដែលបានអនុវត្តនៅពេលដែល GMAC ធ្វើជាប្រធាន នៃក្រុមការងារមួយ ក្នុងវេទិការដ្ឋាភិបាល និងវិស័យឯកជន)។

- ចំណាត់ការរបស់ កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងវិធានការរួមក្នុងវិស័យ និងការសន្ទនា ត្រូវបានកំណត់ឡើងដើម្បីធ្វើឱ្យកំណើន សេដ្ឋកិច្ចមាននិរន្តរភាព ក្រោយពេលគំរោងកត្តាដំបូងត្រូវបានបញ្ចប់។ ដូច្នេះ បញ្ហាចម្បងសំរាប់កម្ពុជា គឺរករកវិធីដើម្បីយកវិធានការទាំងនេះមកអនុវត្តឡើងវិញ ក្នុងវិស័យជាក់លាក់ទាំងនោះ។

**៩.** អំឡុងពេលនៃកំណើនសេដ្ឋកិច្ចឆាប់រហ័ស បានកែប្រែសេដ្ឋកិច្ចបានមួយចំនួនធំ (ជំពូកទី៣) អត្រាភាពក្រីក្រ ត្រូវបានកាត់បន្ថយពី ៤០% ទៅ ៥០% ក្នុងរវាងឆ្នាំ ១៩៩៣ - ១៩៩៤ ចុះមក ៣០% ក្នុងឆ្នាំ ២០០៧។ សូចនាករ សង្គមផ្សេងៗទៀត បញ្ជាក់ច្បាស់ពីការកែលំអរសុខមាលភាពរបស់ប្រជាជនកម្ពុជា។ កត្តាចម្បងដែលជម្រុញ ឱ្យមានសមិទ្ធិផលនេះ គឺការកែប្រែទីផ្សារពលកម្ម និងអន្តរកាលប្រជាសាស្ត្រ។ ក្នុងទីផ្សារពលកម្មការអភិវឌ្ឍន៍ចម្បង គឺការបង្កើតការងារក្រៅវិស័យកសិកម្មពោលគឺនៅក្នុងវិស័យឧស្សាហកម្ម និង សេវាកម្មដោយសារវិស័យទាំងនេះមានផលិតភាពពលកម្មខ្ពស់ជាងវិស័យកសិកម្ម ការបែងចែកពលកម្មឡើងវិញបែបនេះមានផលប៉ះពាល់ធំធេងលើកំណើនសេដ្ឋកិច្ច។ និន្នាការប្រជាសាស្ត្របានបង្ហាញថា មានកំណើនទារក ២ដង នៅដើមទសវត្ស ១៩៨០ និង ១៩៩០ បន្ទាប់មកមានអន្តរកាលប្រជាសាស្ត្រក្នុងទសវត្សឆ្នាំ ១៩៩០ ការកាត់បន្ថយអត្រាអ្នករស់នៅក្នុងបន្ទុកក្នុងទសវត្សកន្លងទៅនេះ (ការបន្ថយអ្នកមានអាយុមិនគ្រប់សំរាប់ការងារ ក្នុងចំណោមពលរដ្ឋដែលមានអាយុគ្រប់សំរាប់ធ្វើការងារ ) ដែលបានចូលរួមពី ១ ទៅ ២% នៃប្រាក់ចំណូលក្នុងបុគ្គលម្នាក់ៗ ក្នុងមួយឆ្នាំៗ។

**១០. វិស័យនេះនាំឱ្យមានសេចក្តីសន្និដ្ឋានបី :**

**<u>ទី១</u> :** ខ្សែកោងកំណើនសេដ្ឋកិច្ចបច្ចុប្បន្ន ទំនងជាមិនមាននិរន្តរភាពខ្លួនឯងបានទេ ដោយសារ (១) មូលដ្ឋាន សេដ្ឋកិច្ចមានសភាពតូចចង្អៀត និងការពង្រីងវិស័យគ្មានការរីកចំរើន។ (២) សមាមាត្រមួយចំនួនធំនៃកំណើនសេដ្ឋកិច្ចក្នុងអតីតកាល ត្រូវបានជំរុញដោយព្រឹត្តិការណ៍ (ដូចជា អន្តរកាលប្រជាសាស្ត្រ និងការកសាងស្ថេរភាព នយោបាយ) ដែលកើតឡើងតែម្តង ឬក្នុងនោះ កំណើនចម្បងដែលពាក់ព័ន្ធនឹងការបង្កើនកំណើនសេដ្ឋកិច្ច ដែលត្រូវធ្វើឡើងដោយរំពឹងថាមានវិភាគទានទាបក្នុងពេលអនាគត។ (៣) ធនធានធម្មជាតិមួយចំនួន ដូចជា ធនធានព្រៃឈើ ត្រូវបានប្រើប្រាស់ដែលគ្មាននិរន្តរភាព និង (៤) ចំណាត់ការអភិបាលកិច្ច ត្រូវបានផ្អែកតាមវិស័យតែប៉ុណ្ណោះ (៥) សមធមិកើតឡើងយ៉ាងលឿននៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ភាពងាយ រងគ្រោះមួយទៀតពាក់ព័ន្ធទៅនឹង វិបត្តិហិរញ្ញវត្ថុសកលលោកនៅចុងឆ្នាំ ២០០៨ ដែលមិនប៉ះពាល់ផ្ទាល់មកលើកម្ពុជាទេ (តែដោយសារវិស័យហិរញ្ញវត្ថុ ខ្សោយរបស់ខ្លួន) ប៉ុន្តែវានឹងធ្វើឱ្យកត្តាជំរុញកំណើនសេដ្ឋកិច្ចដែលមាន ស្រាប់ចុះខ្សោយ។

**<u>ទី២</u>** : ធាតុផ្សំសំខាន់ៗមួយចំនួនសំរាប់សំរាប់របត់ទី២ ត្រូវបានបង្កើតជាស្រេច សារៈសំខាន់នៃស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានចាត់ទុកជាបញ្ហាស្ថាប័ន។ វិស័យកាត់ដេរបានបញ្ជាក់បង្ហាញជាវិធានការអភិបាលកិច្ចគ្រប់គ្រាន់ (និងបរិយាកាសវិនិយោគ) នាំមកនូវកំណើនសេដ្ឋកិច្ច។ តួនាទីនៃអ្នកតាមដានឯករាជ្យ ដែលជាភាគីទី៣ (BFC , ILO)

បានបង្ហាញឱ្យឃើញថា មានអត្ថប្រយោជន៍។ ប្រសិទ្ធិភាពនៃភាពជាដៃគូរវាងវិស័យឯកជន និង ឯកជន (វេទិការដ្ឋាភិបាលនិងវិស័យឯកជន) ត្រូវបានពិសោធន៍ច្បាស់លាស់ពីតួនាទី (និងព្រំដែន) នៃនយោបាយ ឧស្សាហកម្ម ក៏បានបង្ហាញឱ្យឃើញច្បាស់ពីលទ្ធផលរបស់វាដែរ។

**ទី៣** : ប្រជាសាស្ត្រកម្ពុជាក៏ដើរតួនាទីដ៏សំខាន់ក្នុងការធ្វើឱ្យកំណើន មាននិរន្តរភាពដែរ។ ប៉ុន្តែក្រឡេកមើលទៅមុខយើងអាចឃើញថា មានយុវជនកម្ពុជាក្មេងៗពី ២០៩០០០ ទៅ ២៥០០០០នាក់ ចូលក្នុងទីផ្សារពលកម្មរៀងរាល់ឆ្នាំ ដូច្នេះយើងត្រូវការជាចាំបាច់នូវលំហូរការការថ្មីៗ។

## ការកំណត់វិសាលភាព សក្តានុពលកំណើនសេដ្ឋកិច្ចកម្ពុជា

**១១.** ក្នុងបរិបទនៃសមិទ្ធផលដែលទទួលបានការវាយតំលៃខ្ពស់ ប៉ុន្តែនៅផុយស្រួយបែបនេះ និងការធាក់ចុះយ៉ាងលឿននៃសេដ្ឋកិច្ចពិភពលោក យើងអាចធ្វើដូចម្តេចដើម្បីឱ្យកម្ពុជាទទួលបានរបត់ល្អទី២? ឆ្លងតាមការពិនិត្យសក្តានុពលកំណើនសេដ្ឋកិច្ច និងជំរើសសំរាប់ពង្រីកវិស័យកាលវិភាគបានបញ្ជាក់នូវទិសដៅបួនយ៉ាង (ជំពូកទី៤ និង ទី៥)។

**១២.** ទី១ ប្រទេសកម្ពុជានៅតែប្រែប្រទេសដែលមានធនធានដីធ្លីសន្ទឹកសន្ធាប់។ យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចត្រូវតែគោរពតាម ប៉ុន្តែមិនត្រូវជំទាស់នឹងអត្ថប្រយោជន៍ទាំងនេះទេ។ ជាអកុសលបច្ចុប្បន្ននេះ ការបំប៉ោងតំលៃដីធ្លីដោយអសុច្ចរិតបានជំរុញឱ្យតំលៃដីធ្លីឡើងខ្ពស់។ ការឡើងតំលៃក្នុងអត្រាប្តូរប្រាក់រៀលនឹងដុល្លារ (ដោយមានអតិផរណាក្នុងបរិបទប្រាក់រៀលខ្មែរ ទល់នឹងដុល្លារសហរដ្ឋអាមេរិក) ក៏បានបង្កើតតំលៃពលកម្មផងដែរ (បញ្ហាផុសចេញពីទំនាក់ទំនងខ្សោយក្នុងវិស័យឧស្សាហកម្ម ដែលនាំឱ្យមានអត្រាកូដកម្មខ្ពស់) ។ ជាចាំបាច់ត្រូវមានការកែតម្រូវការបំប៉ោងតំលៃអចលនទ្រព្យ ដើម្បីឱ្យកម្ពុជាបង្កើតបាននូវអត្ថប្រយោជន៍ដ៏សំខាន់របស់ខ្លួន។ បើ អាចសំរេចបាននូវសមិទ្ធិផលនេះ កម្ពុជាគប្បបន្តអនុវត្តឱ្យបានល្អក្នុងវិស័យកសិកម្ម ទេសចរណ៍ និងវិស័យផលិត កម្មតូចតាចស្របពេលជាមួយគ្នានេះ កម្ពុជាគប្បធ្វើបច្ចុប្បន្នភាពលើទេយជ្ជទានរបស់ខ្លួន ជាពិសេសតាមរយៈការអប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញអន្តរកាលឱ្យសំរេចដល់អត្ថប្រយោជន៍ថ្មីៗ ក្នុងរយៈពេលមធ្យម។

**១៣.** តួនាទីនៃវិស័យកម្មក្នុងការអភិវឌ្ឍន៍កម្ពុជា នឹងបន្តមានសារៈសំខាន់ ប៉ុន្តែត្រូវតែមានការប្រមើលមើលឱ្យបានច្បាស់លាស់។ បទពិសោធន៍របស់កម្ពុជា និងរបស់ប្រទេសផ្សេងៗ បានបង្ហាញពីតួនាទីដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច តាមវិស័យកសិកម្ម ជាពិសេសក្នុងការកាត់បន្ថយភាពក្រីក្រ (ដោយសារក្នុងចំណោមមនុស្ស ១០នាក់ មានមនុស្សច្រើនទាំង ៩នាក់ ជាអ្នកក្រីក្ររស់នៅតាមជនបទ)។ ប្រទេសកម្ពុជាមានសក្តានុពលល្អច្រើនក្នុងការបង្កើនទិន្នផលស្រូវ និងរួមបញ្ចូលសន្តិសុខស្បៀង។ ហើយការបង្កើននេះផ្តល់កំណើនភាគលាភក្នុងរយៈពេលខ្លី។ ប៉ុន្តែបទពិសោធន៍ក៏បង្ហាញផងដែរថាវិស័យកសិកម្មមិនទំនងជារីកដុះដាលលើសពី ៥% ឬលើសពីនេះបានទេក្នុងមួយឆ្នាំ។ ដូច្នេះវាបានចូលរួមចំណែកតិចជាង ២% នៃកំណើនសេដ្ឋកិច្ចក្នុងមួយឆ្នាំ។ ផលិតកម្មនៅតែមាន សារៈសំខាន់ខ្លាំងក្នុងការស្រូបយក

កំលាំងពលកម្មដដែល។ ហេតុការណ៍ដែលការរៀបចំនគររូបនីយកម្មបានបន្តយ៉ាងយឺត នៅកម្ពុជាក្នុងពេលដែលតំលៃបន្ថែមក្នុងកម្មករម្នាក់ៗ ប្រហាក់ប្រហែលនឹងប្រទេសផ្សេងៗទៀត ក្នុងកំរិតអភិវឌ្ឍន៍ ដូចគ្នានេះ គឺបានបញ្ជាក់ថានៅកម្ពុជាមិនអនុវត្តពេញលេញទេនៅតំបន់ទីក្រុង ។ តួនាទីនៃប្រសិទ្ធិភាពរបស់ការប្រមូលផ្តុំនៅតាម មជ្ឈមណ្ឌលទីក្រុង មិនគប្បីត្រូវបានមើលរំលងទេ ពីព្រោះប្រសិទ្ធិភាពទាំងនេះនឹងរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច បានយ៉ាងច្រើន។

**១៤.** ទីពីរ ក្នុងបច្ចុប្បន្ននេះ កម្ពុជាមានលទ្ធភាពតិចតួចណាស់ដែលចាំបាច់ គប្បីប្តូររកផលិតផលថ្មី។ ការសិក្សាទូទាំងប្រទេសក្នុងពេលថ្មីៗនេះ បានបង្ហាញអោយឃើញថា សំរាប់ឱ្យប្រទេសដែលនាំផលិតផល A ជាញឹកញាប់អាចទាក់ទងនឹងលទ្ធភាពនាំចេញផលិតផល B ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដោយសារគ្មានការពង្រីកផលិតភាពក្នុងទសវត្សកន្លងទៅនេះ មានតែផលិតផលមួយចំនួនតូច " ដែលមានលក្ខខណ្ឌប្រហាក់ប្រហែលគ្នា " ទៅនឹងផលិតផលដែលកម្ពុជាបាននាំចេញ។ កត្តានេះបាននាំឱ្យកម្ពុជាមានជម្រើសតិចតួច ក្នុងការពង្រីកផលិតភាព។ ជាក់ស្តែង ជម្រើសមួយគឺការបង្កើតផលិតផលថ្មីក្នុងវិស័យកាត់ដេរ ប៉ុន្តែផលិតផលមួយចំនួនដែលកម្ពុជាបាននាំចេញរួចហើយ តែការនាំចេញនេះមានកំរិតទាប (ដូចជាផលិតនេសាទនិងព្រៃឈើ) គប្បីត្រូវបានកំណត់ជាអាទិភាព។

**១៥.** ទីបី ការពង្រីកផលិតភាព គប្បីអាស្រ័យតាមទីផ្សារថ្មីៗផងដែរ មិនមែនគិតតែលើផលិតផលថ្មីប៉ុណ្ណោះទេ។ ផ្អែកតាមទស្សនៈនេះ កម្ពុជាមិនទាន់បានអនុវត្តឱ្យបានពេញលេញនៅឡើយទេ បើនិយាតតាមបរិបទទីផ្សារក្នុងតំបន់ (បើប្រៀបធៀបទៅនឹងអត្រាមធ្យម ៤៩% កម្ពុជាមានតែជំនួញ ១៣% ទេ ដែលទាក់ទងនឹងទីផ្សារក្នុងតំបន់)។ មានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីសមាហរណកម្មទៅក្នុងពាណិជ្ជកម្មប្រទេសអាស៊ីចុងបូព៌ា។

**១៦.** ទីបួន ការគ្រងធនធានធម្មជាតិមាននិរន្តរភាព បង្ហាញពីកាលានុវត្តភាពថ្មីមួយទៀត។ ទោះបីជាមូលនិធិបំរុងរបស់ប្រទេសនេះមិនទាន់ច្បាស់លាស់ក៏ដោយ ក៏កម្ពុជាអាចបង្កើតឧស្សាហកម្មចំរាញ់សំខាន់ៗ ដូចជាប្រេង ឧស្ម័ន និងរ៉ែនាទសវត្សខាងមុខ។ ដើម្បីធានាកម្ពុជាទទួលភាគលាភកំណើនសេដ្ឋកិច្ចពីវិស័យនេះកម្ពុជាត្រូវបង្កើនគុណភាពការគ្រប់គ្រងក្នុងវិស័យ ដែលក្នុងពេលបច្ចុប្បន្ននេះមិនទាន់មានប្រសិទ្ធិភាព និងស្មុគស្មាញខ្លាំង។ អាទិភាពទាំងបីក្នុងវិស័យរួមមាន : (១) គប្បីបកស្រាយបំភ្លឺក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន និងក្របខណ្ឌស្ថាប័នដើម្បីកែលំអគណនេយ្យភាព (២) កសាងធនធានមនុស្សដើម្បីអនុវត្តគណនេយ្យភាពនេះ ដោយទទួលស្គាល់ថាត្រូវប្រើពេលវេលាដើម្បីកសាងសមត្ថភាពដែល ត្រូវការក្នុងវិស័យ និងត្រូវបង្កើតជាបន្តបន្ទាប់រួមជាមួយវិស័យផ្សេងទៀត និង (៣) ត្រូវគ្រប់គ្រងសេចក្តីរំពឹងទុកក្នុងន័យឧបត្ថម្ភធនសំរាប់ផលិតផលប្រេងឥន្ធនៈនិងរ៉ែឬការផលិតនិងចែកចាយ។

**១៧.** បើការអនុវត្តដូច្នេះត្រូវសំរេចបាន ប្រទេសនេះអាចមានលទ្ធភាពបន្តនិរន្តរភាពកំណើនសេដ្ឋកិច្ចពី ៦ ទៅ ៧ ភាគរយក្នុងមួយឆ្នាំក្នុងរយៈពេលមធ្យម (ទោះបីជាទស្សនវិស័យរយៈពេលខ្លី មិនសូវមានការជំរុញទឹកចិត្តដោយសារបរិយាកាសសាកលលោកក៏ដោយ)។ វាជា កត្តាដែលមិនអាចធ្វើទៅបាន ហើយទំនងជាមិនជាទីប្រាថ្នាចង់បាន ដោយសារការចង្អុលបង្ហាញតាមការវិភាគដែលផលិតផលមួយ ឬទីផ្សារមួយដែលនឹងងើបឡើងវិញ អាចនាំឱ្យរបត់ថ្មីកើតឡើងបាន ប៉ុន្តែអ្នកធ្វើគោលនយោបាយនិងសហគ្រិនត្រូវ "យកវាជាការសាកល្បង " អត្រាកំណើនដែលមាននិរន្តរភាពកំណើនសេដ្ឋកិច្ចមធ្យមពី ៦ ទៅ ៧ ភាគរយក្នុងមួយឆ្នាំ អាចនឹងស្រប ទៅតាម : (១) បទពិសោធន៍អន្តរជាតិដែលផ្អែកទៅលើគុណភាពនៃកត្តាជំរុញកំណើនឱ្យមានមួយចំនួន (ដូចជាការ អភិវឌ្ឍន៍ ការអប់រំ និងវិស័យហិរញ្ញវត្ថុ) និង (២) ការវិនិយោគជាបន្តក្នុងធនធានមនុស្ស និងមូលធនរូបវន្ត។

## ការកំណត់អត្តសញ្ញាណឧបសគ្គ

**១៨.** ដើម្បីសម្រេចបានសក្តានុពលនេះ ជាចាំបាច់ត្រូវតែកំណត់ឱ្យបានច្បាស់ពីឧបសគ្គដែលរារាំងកំណើនសេដ្ឋកិច្ច។ នៅក្នុងប្រទេសដែលមានចំណូលទាប និងអភិបាលកិច្ចក៏រិតទាប ដូចករណីប្រទេសកម្ពុជា ដើម្បីមានការងាយស្រួលយើងគប្បីចាត់ទុកអ្វីៗ សុទ្ធតែជាឧបសគ្គទាំងអស់។ ប៉ុន្តែមិនមែនមានតែចំណុចនេះមួយមុខគត់ ដែលជាបទពិសោធន៍កំណើនឆាប់រហ័សក្នុងទសវត្សរកន្លងមកនោះទេ ផ្ទុយទៅវិញ ការចាត់ទុកបទពិសោធន៍នេះជាយុទ្ធសាស្ត្រ មិនសូវមានប្រយោជន៍ទេ។ វិធីសាស្ត្រសំរាប់កំណត់អត្តសញ្ញាណ និងអាទិភាពឧបសគ្គ ត្រូវអង្កេតរកឱ្យឃើញនូវមូលហេតុដែលនាំសហគ្រិនមិនធ្វើវិនិយោគបន្ថែបសំរាប់កសាងសមត្ថភាពថ្មី ផលិតផលថ្មី ឬដើម្បីកែលំអផលិតភាព។ ចម្លើយអាចថា ដោយសារផលរបរដែលទទួលបានពីការវិនិយោគដែលមានសក្តានុពលនោះ មានក៏រិតទាបពេក ឬការចំណាយសំរាប់ហិរញ្ញប្បទានគំរោងទាំងនេះខ្ពស់ពេក។

**១៩.** ទើបតែថ្មីៗនេះ មានភស្តុតាងតិចតួចដែលបញ្ជាក់ថា ហិរញ្ញវត្ថុជាឧបសគ្គក្នុងក៏រិតធ្ងន់ធ្ងរ។ ជាទូទៅ វិស័យហិរញ្ញវត្ថុមានលក្ខណៈងាយស្រួល (ឧទាហរណ៍ អនុបាតពីប្រាក់កម្ចីទៅប្រាក់បញ្ញើគឺ ៦៤ ភាគរយ)។ អនុបាតនេះមានវិវឌ្ឍយ៉ាងលើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងរយៈពេលប៉ុន្មានកន្លងទៅនេះ ហើយអត្រាការប្រាក់របបពិតបានចុះដល់តួលេខអវិជ្ជមាន ក្នុងរយៈពេលថ្មីៗនេះ។ អត្រាការប្រាក់របបពិតនិងវិនិយោគលើឧបករណ៍ដែលមានអាយុកាលវែង បានកើនឡើងស្របគ្នា ដែលជាកត្តាបង្ហាញថាមានឧបសគ្គចំពោះតម្រូវការ តែមិនមានឧបសគ្គលើការផ្គត់ផ្គង់ទេ។ មានការលើកលែងពីរដែលយើងមើលឃើញច្បាស់។ ទីមួយ មានការលំបាកក្នុងការអនុវត្តគំរោងវិនិយោគធំៗ ពោលគឺវាមានទំនាក់ទំនងតែទៅវិនិយោគបរទេស ដែលធ្វើឱ្យគំរោងទាំងនេះអាចដំណើរការបាន។ ទីពីរ លទ្ធភាពទទួលបានហិរញ្ញវត្ថុសំរាប់គំរោងកសិកម្ម នៅតែមិនគ្រប់គ្រាន់ និងជាឧបសគ្គលើលទ្ធភាពកសិករក្នុងការកែលំអផលិតភាព។ លើសពីការលើកលែងទាំងពីរខាងលើនេះ មានភស្តុតាងដែលយើងសង្កេតឃើញថា ហិរញ្ញប្បទានមួយភាគធំ ដែល

កើតចេញពីប្រាក់សន្សំបរទេស (ឧទាហរណ៍ សូចនាករដែលបង្ហាញថាកំណើន សេដ្ឋកិច្ចនិងគណនីចរន្ត មាននិន្នាការស្របគ្នា) ហើយបញ្ជាក់ច្បាស់ពីផលប៉ះពាល់សក្តានុពលនៃលក្ខខណ្ឌហិរញ្ញវត្ថុ ខ្លាំងជាងនៅក្នុងទីផ្សារអន្តរជាតិ។

**២០.** ដូច្នេះបញ្ហានៅត្រង់ថាហេតុអ្វីបានជាសហគ្រិនមិនអាចកំណត់យកគំរោងដែលផលរបរខ្ពស់បាន។ ក្នុងបរិបទនេះអាចមានសេចក្តីសន្និដ្ឋានពីរ ទីមួយ និយាយដោយសាមញ្ញបានថា ដោយសារមានគំរោងដែលផ្តល់ផលរបរតិចតួចណាស់ (ដោយសារថ្លៃចំណាយក្នុងការផលិតខ្ពស់ហួសហេតុ ឬបញ្ហាសម្របសម្រួល) ឬសហគ្រិនរំពឹងថាពួកគេនឹងមិនអាចចាប់យកផលរបរគ្រប់គ្រាន់ដោយខ្លួនឯងបានទេ (ដោយសារហានិភ័យនៅក្នុងបរិយាកាសពាណិជ្ជកម្ម ឬចំណាយពន្ធអាករផ្លូវការ ឬក្រៅផ្លូវការ)។ បញ្ហាទំនងជាមិនមែនស្ថិតនៅតែត្រង់ថ្លៃចំណាយផលិតជាចម្បងនោះទេ ប៉ុន្តែគឺបញ្ហាការសម្របសម្រួល និងការទាញយកផលរបរទាំងនោះផងដែរ។ តាមពិត កត្តាសំខាន់បំផុតនៃសេដ្ឋកិច្ចគឺ ផលិតភាពនៃការីសេដ្ឋកិច្ចកំពូលៗ (ក្នុងករណីមួយចំនួនតូច គឺតំលៃស្មើក្នុងប្រទេសដែលមានការអភិវឌ្ឍន៍ខ្លាំង) ដែល មានការពង្រីកសមិទ្ធផលយ៉ាងទូលំទូលាយក្នុងចំណោមក្រុមហ៊ុននានា ដែលស្ថិតក្នុងវិស័យភាគច្រើន ជាមធ្យមក្រុមហ៊ុនទាំងនោះដំណើរការផលិតភាពបាន ៦០% ឬទាបជាងការីសេដ្ឋកិច្ចកំពូល។

**២១.** ការសម្របសម្រួលគឺជាបញ្ហាចំបងមួយ។ បើនិយាយពីផលិតកម្ម ជាពិសេសចំពោះផលិតផលថ្មីៗ តម្រូវឱ្យមានកិច្ចសហការពីការីសេដ្ឋកិច្ចមួយចំនួនស្របតាមខ្សែចង្វាក់តម្លៃ និងការបង្កើតវិធាន ឬបទបញ្ញត្តិមួយចំនួនសម្រាប់គ្រប់គ្រងប្រត្តិបត្តិការពាណិជ្ជកម្មនានា។ កត្តានេះ មានសារៈសំខាន់ជាពិសេសចំពោះ "ការរកឃើញដោយខ្លួនឯង" ឧទាហរណ៍ការរកឃើញថា "តើប្រទេសកម្ពុជាពូកែខាងអ្វី"។ កត្តាដែលបង្ហាញពីការលំបាកក្នុងកិច្ចសហការទាំងនេះរួមមាន : (១) កង្វះនៃការពង្រីកវិស័យសំរាប់ផលិតផលថ្មីក្នុងទសវត្សកន្លងទៅនេះ (២) ភាពសាមញ្ញនៃខ្សែចង្វាក់តម្លៃរបស់ផលិតផលភាគច្រើនដែលផលិតនៅកម្ពុជា (ឧទាហរណ៍ ក្រុមហ៊ុនកាត់ដេរភាគច្រើនគឺជាក្រុមហ៊ុន "កាត់-ផ្គុំ-តម្រឹម" ដែលជាខ្សែចង្វាក់តម្លៃសាមញ្ញបំផុត) និង (៣) តថភាពដែលបង្ហាញថាផលិតផលកសិកម្មភាគច្រើនត្រូវបាននាំចេញជាទំនិញវត្ថុធាតុដើម (ឧទាហរណ៍ ស្រូវគ្រាប់ស្វាយចន្ទីទាំងសំបក កៅស៊ូក្រែប)។ ចំណុចទាំងនេះបង្ហាញពីបញ្ហាធំធេងមួយក្នុងកិច្ចសហការដើម្បីធ្វើឱ្យមានខ្សែសង្វាក់តម្លៃដែលស្មុគស្មាញជាងនេះ។ ក្នុងអតីតកាលកិច្ចសហការនេះ ធ្លាប់កើតមាននៅក្នុងប្រទេសកម្ពុជា ជាពិសេសតាមរយៈយន្តការអភិបាលកិច្ចដែលមានការប្តេជ្ញាច្បាស់លាស់ (ឧទាហរណ៍ វិស័យកាត់ដេរ)។

**២២.** បញ្ហាក្នុងការចាប់យកគឺមានភាពធំធេង ក្នុងកំរិតម៉ាក្រូ និងមីក្រូ។ អស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច គ្រាន់តែជាបញ្ហាព្រួយបារម្ភថ្មីមួយ ហើយត្រូវមានការដោះស្រាយជាបន្ទាន់តែប៉ុណ្ណោះ (អស្ថេរភាពតម្លៃផលិតផ្សេងៗ ទៀតដូចជាបទល្មើសឬសន្តិសុខ មិនមែនជាការព្រួយបារម្ភខ្លាំងដូចពី១០ឆ្នាំមុននោះទេ)។ មានបញ្ហាម៉ាក្រូសេដ្ឋកិច្ចពីរប្រភេទដែលធ្វើឱ្យសហគ្រិនមិនអាចចាប់យកផលរបរពីទុនវិនិយោគរបស់គេបាន : (១) ដោយសារកង្វះខាតប្រពន្ធតុលាការដែល

មានប្រសិទ្ធិភាពវិវាទ (ក្នុងពាណិជ្ជកម្ម និងពលកម្ម) បានក្លាយទៅជាការព្រួយបារម្ភយ៉ាងខ្លាំង និង (២) នៅមានអំពើពុករលួយគ្រប់កន្លែង និងគ្រប់រូបភាពនៅឡើយ ។ គួរកត់សំគាល់ថា ពាក់ព័ន្ធនឹងបញ្ហាទាំងពីរនេះក្រុមហ៊ុនជាច្រើនបានរកឃើញយុទ្ធសាស្ត្រសំរាលបន្ទុក (ដូចជាការលក់ដែលតម្រូវឱ្យបង់ប្រាក់មុន ដើម្បីជៀសវាង វិវាទ ការចុះកិច្ចព្រមព្រៀងសមូហភាព ដើម្បីកាត់បន្ថយបាតុភាពវិវាទការងារ ការរក្សាទុកទម្រង់អាជីវកម្មជា អាជីវកម្មក្រៅផ្លូវការ ។ល ។ បើប្រៀបធៀបទៅនឹងចំណាយរដ្ឋបាល ក៏វិតចំណាយពន្ធអាករមិនមែនជាឧបសគ្គ ចម្បងឡើយ ។

**២៣.** ក្នុងបរិបទតម្លៃផលិត ថ្លៃចរន្តអគ្គិសនី និងការដឹកជញ្ជូនខ្ពស់ បានក្លាយទៅជាបញ្ហាព្រួយបារម្ភចម្បង។ សារសំខាន់នៃបញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុង : (១) ឆន្ទៈរបស់ក្រុមហ៊ុនក្នុងការផលិតចរន្តអគ្គិសនី ៣៦% ដោយខ្លួនឯងដោយប្រើម៉ាស៊ីនភ្លើងដែលមានតម្លៃខ្ពស់ (២) កង្វះការវិនិយោគក្នុងវិស័យអគ្គិសនីដែលទូលំទូលាយ (ឧស្សាហកម្មកាត់ដេរជាឧស្សាហកម្មធុនស្រាល បើប្រៀបធៀបទៅនឹងវិស័យនេះ) (៣) កិច្ចប្រឹងប្រែងរបស់ក្រុមហ៊ុនកាត់ដេរក្នុងការបន្ថយចំណាយដឹកជញ្ជូន និងពន្ធគយ (ក្នុងរយៈពេលបួនឆ្នាំកន្លងទៅនេះ ថ្លៃចំណាយសំរាប់ដឹកទំនិញឆ្លងតាមគយបានចុះថោកចំពោះក្រុមហ៊ុនកាត់ដេរ ប៉ុន្តែបានកើនឡើងចំពោះផលិតករ ស្រូវអង្ករ) និង (៤) ក្រុមហ៊ុនរក្សាទុកសារពើភណ្ឌក្នុងរយៈពេលយូរ (៤១ថ្ងៃ លើវត្ថុធាតុចូល បើធៀបទៅនឹង ប្រទេសភាគច្រើនគេប្រើពេលតិចជាង៣០ថ្ងៃ) ។ សេវាដឹកជញ្ជូននិងភស្តុភារ មានឧបស័គ្គដោយសារការសម្រួល ពាណិជ្ជកម្មនៅខ្សោយ និងនីតិវិធីឆ្លងកាត់ព្រំដែនដែល ស្មុគស្មាញ។ ផ្លូវលំជនបទដែលមានក៏វិតបង្កើតជាឧបសគ្គ យ៉ាងធំចំពោះសក្តានុពលកសិកម្មកម្ពុជា។ តម្លៃពលកម្មនៅទាបនៅឡើយ ប៉ុន្តែដូចបានកត់សំគាល់ខាងលើការឡើងថ្លៃ យ៉ាងលឿននៃប្រាក់រៀលខ្មែរ ក្នុងល្បឿនជាក់ស្តែងនេះ កំពុងតែធ្វើផលធៀបសេដ្ឋកិច្ចចុះខ្សោយ បើគ្មានការ ដោះស្រាយទេ វានឹងធ្វើឱ្យប្រតិបត្តិការ វិស័យកាត់ដេរចុះខ្សោយ និងរារាំងការពង្រីកវិស័យផ្សេងក្នុង អនាគតបាន។

## របត់កំណើនថ្មីមួយ?

**២៤.** រាជរដ្ឋាភិបាលកម្ពុជាមានយុទ្ធសាស្ត្រអភិវឌ្ឍ ដែលហៅថាផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដែលបានបញ្ជាក់ពីគោលដៅ និងអាទិភាពគោលនយោបាយនានា ដូចបានកំណត់ក្នុងកម្មវិធីនយោបាយរបស់រដ្ឋាភិបាល (យុទ្ធសាស្ត្រចតុកោណដែលដំណាក់កាលទីពីរនៃយុទ្ធសាស្ត្រនេះ ត្រូវបានធ្វើឧទ្ទេសនាមដោយរដ្ឋាភិបាលថ្មីក្នុងខែកញ្ញា ឆ្នាំ ២០០៨) ។ ឯកសារយុទ្ធសាស្ត្រទាំងនេះ សង្កត់ធ្ងន់ទៅលើធាតុផ្សំសំខាន់ៗ នៃយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ច ។ កាងវិភាគខាងដើម គឺជាវិភាគទានសំរាប់ការស្វែងយល់កត្តាជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា ទាំងក្នុងអតីតកាល និងនាពេលអនាគត ក្នុងទស្សនៈដើម្បីតម្រែតម្រង់ ឬកំណត់អាទិភាពសកម្មភាពនានាដើម្បីធានាឱ្យកំណើនសេដ្ឋកិច្ចដែលឆាប់រហ័សមាននិរន្តរភាព និងកែតំរូវយុទ្ធសាស្ត្រស្របទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចមច្ចុប្បន្ន ។

**២៥.** ផ្អែកតាមប្រវត្តិនេះ តើត្រូវមានចំណាត់ការអ្វីខ្លះក្នុងបរិបទបច្ចុប្បន្ន ដែលអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចដែលឆាប់រហ័សមាននិរន្តរភាព? វិស័យមួយចំនួនត្រូវបានកំណត់អាទិភាពផ្អែកតាមការវិភាគខាងលើ ។ របាយការណ៏នេះសង្កត់ធ្ងន់

លើលិខិតឧបករណ៍ចំនួនបី :(១) គោលនយោបាយអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ (២) គោលនយោបាយសារពើពន្ធ និង (៣) នយោបាយគ្រប់គ្រង/ពាណិជ្ជកម្ម/ឧស្សាហកម្ម (ប្រអប់ទី១ បង្ហាញពីបញ្ជី បកស្រាយអំពីសក្តានុពល "ឈ្នះ ឆាប់ ") ។ ដើម្បីទទួលបានរបត់កំណើនសេដ្ឋកិច្ចថ្មី មធ្យោបាយសំខាន់ៗបី ត្រូវបានផ្តល់អាទិភាព (ជំពូកទី ៧-៩) ។

**២៦.** អាទិភាពទីមួយគឺត្រូវធ្វើសមាហរណកម្មកម្ពុជាឱ្យបានជ្រៅទៅក្នុងតំបន់។ ការបន្ថយល្បឿននៃពាណិជ្ជកម្មពិភពលោក បញ្ជាក់ថាគោលដៅនេះគឺជាការបន្ទាន់ ។ តាមការជាក់ ស្តែងការសម្របសម្រួលពាណិជ្ជកម្ម (នៅតាមព្រំដែន និងខាងក្រោយព្រំដែន) គឺជាប្រការសំខាន់ណាស់ ។ ប៉ុន្តែអាទិភាពគឺមួយនេះ គប្បីផ្តោត អារម្មណ៍ឱ្យបានខ្លាំងទៅលើការបញ្ចូលក្រុមហ៊ុនកម្ពុជាទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់សកលលោក ពោលគឺធ្វើឱ្យក្រុមថៃ ចិន និង ក្រុមហ៊ុនវៀតណាម សម្លឹងមើលកម្ពុជាដើម្បីបោះទីតាំងរោងចក្ររបស់គេ បើអាចទៅធ្វើបាន ។ កម្ពុជាអាចប្រើអាស៊ាន ជាយានសំរាប់គំនិតផ្តួចផ្តើមថ្មីរបស់ខ្លួនក្នុងវិស័យទាំងនេះ។ កម្ពុជាគប្បីពិចារណាលើវិធានការទាំងដូចខាងក្រោមនេះ ។

- អាទិភាពជាបន្ទាន់សំរាប់កម្ពុជាគឺត្រូវដោះស្រាយហានិភ័យក្នុងវិស័យហិរញ្ញវត្ថុរបស់ខ្លួនជាចាំបាច់ (ឧទា. ពង្រឹងលក្ខណវិនិច្ឆ័យ ធនាគារ បន្តកិច្ចប្រឹងប្រែងតាមដានប្រាក់កម្ចីអកម្ម) និងគ្រប់គ្រងគោល-នយោបាយចំរុះ (បញ្ចូលសម្ពាធ ពីអតិផរណា ប៉ុន្តែគាំទ្រកំណើនសេដ្ឋកិច្ច)។ ក្នុងពេលជាមួយគ្នានេះ ប្រការចាំបាច់គឺត្រូវគ្រប់គ្រងអត្រា ប្តូរប្រាក់ឱ្យបានសកម្មជាងនេះ ដោយសារសេដ្ឋកិច្ចស្ថិតក្នុងរបបដុល្លារូបនីយកម្មខ្លាំង កម្ពុជាកំពុងតែបាត់បង់អត្ថប្រយោជន៍ធៀបខាងតម្លៃផលលិតទាបយ៉ាងឆាប់រហ័ស ដោយសារប្រាក់ដុល្លារឡើងថ្លៃ និង អតិផរណា។ ប្រការសំខាន់ ត្រូវដោះស្រាយបញ្ហានេះឱ្យបានឆាប់រហ័ស ដោយសារប្រាក់ចំណូលធំពីឧស្សាហកម្មចំរាញ់ និងធ្វើបញ្ហាកាន់តែមានភាពធ្ងន់ធ្ងរនាពេលអនាគត។
- បន្ថែមពីលើនេះប្រទេសកម្ពុជាគួរតែចាប់យកនូវឱកាសវិជ្ជមាននៅពេលដែលលំហូរ ពាណិជ្ជកម្ម និង ការវិនិយោគទុនចាប់ផ្តើមវិលមកដើមវិញ ។ ពាណិជ្ជកម្ម និង ការវិនិយោគអាចត្រូវបានសម្រួលល្អជាងបច្ចុប្បន្ន ជាពិសេស សង្កត់ធ្ងន់លើកសិ-ឧស្សាហកម្ម។ គោលបំណងនេះអាចសំរេចបានតាមរយៈការបង្កើតអង្គភាពដែលមានចេតនា ផ្តល់សេវា កម្មវិនិយោគិនវិស័យកសិ-ឧស្សាហកម្ម និង តាមរយៈការបង្កើតអង្គភាពតាមដានឯករាជ្យ លើស្តង់ដារ អនាម័យ និងភូតគាមអនាម័យ (តាមគំរូ របស់កម្ពុជារោងចក្រល្អ សំរាប់ស្តង់ដារពលកម្ម)។ ការបង្កើត ទិន្នផលស្រូវឱ្យបានទ្វេគុណ ត្រូវមានវិធីសាស្ត្រសម្របសម្រួលសំរាប់បង្កើតចំណេះដឹង និងការលើកទឹកចិត្តដល់កសិករឱ្យប្រើគ្រាប់ពូជស្រូវ និងជីដែលសមស្រប។ ការធ្វើឱ្យការលើកទឹកចិត្តខាងពន្ធអាករដែលមានស្រាប់កាន់តែសកម្ម ក៏អាចនាំមកនូវប្រាក់ចំណូលមួយចំនួនធំដែរ។

- ទីបញ្ចប់ ការសិក្សាវិភាគអំពីឧបស័គ្គកំណើនសេដ្ឋកិច្ច បានសង្កត់ធ្ងន់ពីសារសំខាន់នៃបញ្ហាសម្របសម្រួល។ ក្រៅពីអង្គភាពផ្តល់សេវាជូនវិនិយោគិន និងអង្គភាពតាមដានស្តង់ដារ (ចំណុចខាងដើម) ត្រូវមានការគាំទ្រដល់សមាគមន៍អាជីវកម្ម ការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលមានភាពគាំទ្រជាងមុន និងត្រូវមានការពិចារបង្កើនលទ្ធភាពប្រើប្រាស់ផលិតផលហិរញ្ញវត្ថុ (រួមទាំងតាមរយៈ ការិយាល័យឥណទានដែលដំណើរការល្អ)។ កម្មវិធីសំខាន់មួយសំរាប់កំណត់ និងដោះស្រាយបញ្ហាព្រួយបារម្ភរួមគឺវេទិការដ្ឋាភិបាលនិងវិស័យឯកជន (បញ្ហានេះ តម្រូវឱ្យវេទិកានេះរៀបចំការសិក្សានិងវិភាគជាច្រើនទៀត)។ ក្រៅពីនេះ គប្បីមានការគាំទ្រសមាគមន៍អាជីវករមួយចំនួន ដូចជាសមាគមន៍ ឧស្សាហកម្មសំរាប់សណ្ឋាគារ និងឧស្សាហកម្មកាត់ដេរ ដើម្បីកំណត់បញ្ហារួមដែលប៉ះពាល់ផលិតភាព និងលើកសំណើវិធានការ ដើម្បីពង្រីកផលិតភាពនៅក្នុងវិស័យ (ជាពិសេស ពួកគេនឹងមានតួនាទីក្នុងការដោះស្រាយបញ្ហាការបណ្តុះបណ្តាល)។ តាមពិតរាជរដ្ឋាភិបាល និងវិស័យឯកជនត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាដើម្បីកំណត់ឧបស័គ្គ និង កាលានុវត្តភាពសំខាន់ៗ ។ តួនាទីនៃកិច្ចសម្របសម្រួលក្នុងវិស័យកសិកម្មមានសារសំខាន់ណាស់ ហើយអនុវត្តតាមរូបភាព កសិដ្ឋានតាមកិច្ចសន្យា សមាគមន៍កសិករសហការណ៍កសិករ ក្រុមជួយខ្លួនឯង ។ល។

**២៧.** ទីពីរ ការវិភាគនេះបានសង្កត់ធ្ងន់លើសារសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិដែលមាននិរន្តរភាព ។ កម្ពុជាមានបទពិសោធន៍ទាំងពីរ គឺបទពិសោធន៍ល្អ (ឧទាហរណ៍ ការអភិវឌ្ឍសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ) និងបទពិសោធន៍អាក្រក់ (ឧទាហរណ៍ ការកាប់ឈើខុសច្បាប់) សំរាប់ធ្វើជាបង្អែក ។ ការអភិវឌ្ឍន៍ឧស្សាហកម្មនាពេលអនាគត ផ្តល់ទាំងកាលានុវត្តភាព និងឧបស័គ្គធំៗមួយចំនួន ។

អាទិភាពក្នុងវិស័យនេះ រួមមាន :

- គប្បីមានគំនិតផ្តួចផ្តើមក្នុងកិច្ចប្រឹងប្រែងគ្រប់គ្រងធនធានដែលមានស្រាប់ ដែលរាប់បញ្ចូលទាំងការកំណត់ព្រំដែនព្រៃឈើ សហគមន៍ពៃឈើ និងនេសាទ និងការគ្រប់គ្រងដីរដ្ឋ។ ការសម្របសម្រួលវិស័យទេសចរណ៍ក៏ត្រូវមានការកែរលំអរផងដែរ។
- វិស័យឧស្សាហកម្មនិស្សារណកម្ម គឺមានលក្ខណះសំខាន់ណាស់ដែលបានបន្លឺជាបរិយាកាសមួយសំរាប់ទាក់ទាញអ្នកវិនិយោគទុននៅកម្ពុជា ។ ក្របខណ្ឌច្បាប់ និងសារពើពន្ធត្រូវធ្វើជាបន្ទាន់សំរាប់វិស័យឧស្សាហកម្មចំរាញ់ រួមទាំងវិស័យប្រេង ឥន្ទនៈ និងរ៉ែ។ រាជរដ្ឋាភិបាលកម្ពុជាគប្បីកសាងសមត្ថភាពរបស់ខ្លួន ដើម្បីគ្រប់គ្រងវិស័យនេះរួមបញ្ចូល ទាំងតាមរយៈការបណ្តុះបណ្តាលប្រើប្រព័ន្ធកំព្យូទ័រ ការអភិវឌ្ឍន៍ប្រព័ន្ធសុរិយោដីល្អ ។ល។ ប្រសិនបើ និងកាលណាមូលដ្ឋានចំណូលមានទំហំធំ គប្បីប្រើយន្តការតាមដានឯករាជ្យដូចគំរោងកម្ពុជារោងចក្រល្អ ដើម្បីពង្រឹងគណនេយ្យភាពក្នុងវិស័យនេះ (ជាពិសេស ក្នុងការប្រមូលចំណូលគំនិតផ្តួចផ្តើមតម្លាភាពក្នុងឧស្សាហកម្មចំរាញ់ ផ្តល់នូវបែបបទ និង សញ្ញាសំរាប់ពង្រឹងគណនេយ្យភាព និងបង្ហាញពីការប្តេជ្ញាចិត្ត របស់កម្ពុជាចំពោះគោលការណ៍តម្លាភាព ។

**២៨.** ទីបី ក្នុងរយៈពេលមធ្យម កម្ពុជាគប្បីអភិវឌ្ឍន៍ទាយជ្ជទានរបស់ខ្លួន ដើម្បីឈានទៅដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍន៍ ។ ក្នុងខណៈដែលខ្លួនមិនទាន់សំរេចបាននូវអត្ថប្រយោជន៍ធៀបនេះ កម្ពុជាអាចអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពធនធានមនុស្ស និងគៀងគរប្រាក់សន្សំថែមទៀត ដើម្បីត្រៀមខ្លួនទាញយកកំណើនសេដ្ឋកិច្ចនាពេលអនាគត ។

- ជាបឋម ការកែលំអគុណភាពផ្លូវលំជនបទ វិស័យកសិកម្មដែលជាគុណប្រយោជន៍សាធារណៈ គឺជាបញ្ហាអាទិភាព (ការសិក្សាស្រាវជ្រាវ និងការបន្តការស្រាវជ្រាវ) និង ទុនធនធានមនុស្ស (បន្តសង្កត់ធ្ងន់លើការអប់រំថ្នាក់បឋមសិក្សា ដើម្បីពង្រឹងចំណូលមូលដ្ឋាន)។ ប៉ុន្តែ ក្នុងគ្រប់ករណីទាំងអស់ ការចំណាយខ្ពស់មិនមែនជាការគ្រប់គ្រាន់ទេ ផ្ទុយទៅវិញ គុណភាពនៃការចំណាយ (រួមទាំងការដោះស្រាយបញ្ហាស្ថាប័ន និងការកំណត់ថ្លៃចរន្តអគ្គិសនី ការថែទាំផ្លូវថ្នល់ និងគុណភាពនៃការបង្រៀន) និងបង្កបញ្ហាច្រើនជាងក៏រិតនៃការចំណាយទៅទៀត។ ទំហំសារពើពន្ធដែលមានកំរិត ក៏តម្រូវឱ្យមានកិច្ចប្រឹងប្រែងខ្លាំង ក្នុងការកំណត់អាទិភាពការចំណាយថវិការ ដោយផ្អែកលើការ វិភាគចំណាយ- លទ្ធផលត្រឹមត្រូវ (ឧទាហរណ៍ មានភស្តុតាងបង្ហាញថា ផលរបរពីហេដ្ឋារចនា សម្ព័នជនបទក្នុងបរិបទទិន្នផល ស្រូវ ខុសគ្នាឆ្ងាយរវាងតំបន់នានា)។
- ការគៀងគរប្រាក់សន្សំក្នុងស្រុក នឹងក្លាយទៅជាកត្តាដែលកាន់តែសំខាន់ សំរាប់ធ្វើហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ និងការអប់រំ។ ការពង្រឹងទំហំសារពើពន្ធ ជាពិសេសតាមរយៈការបង្កើតមូលដ្ឋានប្រាក់ចំណូល ក៏នឹងមានសារសំខាន់ក្នុងបរិបទនេះដែរ។
- ដើម្បីគ្រប់គ្រងរបៀបវារៈសំរាប់រយៈពេលមធ្យមនេះ កំណែទម្រង់វិស័យសាធារណៈមួយចំនួន និងរិតតែមានសារសំខាន់។

**២៩.** នៅទីបញ្ចប់ របាយការណ៍នេះកំណត់វិស័យបីសំរាប់ការវិភាគបន្ត ដោយសារវិស័យទាំងនេះនឹងកែលំអបញ្ហាប្រឈម។ ទោះបីជាវិស័យទាំងនេះនឹងមិននាំមកនូវភាគលាភកំណើនសេដ្ឋកិច្ចភ្លាមៗ ក៏ដោយ ក៏ត្រូវតែមានការវិភាគលើវិស័យទាំងនេះឱ្យបានល្អិតល្អន់នាពេលអនាគត ដើម្បីអាចដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចបាន។ ត្រូវមានការគ្រប់គ្រង *ការអភិវឌ្ឍន៍ជាយក្រុង* ឱ្យបានត្រឹមត្រូវ ដោយសារសក្តានុពលកំណើនសេដ្ឋកិច្ចក្នុងទីប្រជុំជន និងហានិភ័យនៃការគ្រប់គ្រងមិនល្អ (ដូចជាការស្ទះចរាចរណ៍ សេវាកម្មខ្សោយ។ល។ ដែលនឹងអាចកាត់បន្ថយការលើកទឹកចិត្តនៃវិនិយោគ និងបង្កើនថ្លៃចំណាយដល់ក្រុមហ៊ុនដែលមានស្រាប់)។ ការពឹងផ្អែកលើចរិកលក្ខណៈរបស់វាកំណើនឆាប់រហ័សអាចជំរុញឱ្យមាន *អសមភាព* ។ មានសូចនករមួយចំនួនបានបង្ហាញថា អសមភាព មានការកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ។ ដូចជា កំណើនឆាប់រហ័សនៃអសមភាព មិនត្រឹមតែមានបាតុ

ភាពដែលយើងមិនប្រាថ្នាចង់បានក្នុងបរិបទនយោបាយ និងសង្គមតែប៉ុណ្ណោះទេ តែវាក៏មានផលអាក្រក់ចំពោះកំណើនសេដ្ឋកិច្ចដែលមាននិរន្តរភាពដែរ ។ ដូចដែលបានលើកឡើងនៅសំរាប់ការលើកឡើងតំលៃម្ហូបអាហារ និងវិបត្តិហិរញ្ញ-វត្ថុពិភពលោក ការគ្រប់គ្រងឱ្យបានប្រសើរ ក៏ដូចជា ការកំណត់គោលដៅឱ្យបានប្រសើរចំពោះសំណាញ់សុវត្ថិភាពសង្គម គឺជាមធ្យោបាយដ៏សំខាន់មួយសំរាប់កាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចចំពោះអ្នកដែលងាយរងគ្រោះ ។ ចុងក្រោយគឺ *បរិស្ថាន* ។ បរិស្ថានគឺទ្រព្យសម្បត្តិមួយសំរាប់ប្រទេសកម្ពុជា ប៉ុន្តែកំណើនឆាប់រហ័សនិងការវិវឌ្ឍន៍ក្នុងសាកលលោក ដូចជាការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យបរិស្ថានមានបញ្ហា ។

៣០. ប្រទេសកម្ពុជាបានកសាងការរីកចំរើនយ៉ាងរឹងមាំដោយសារកំណើនសេដ្ឋកិច្ចឆាប់រហ័សរបស់ខ្លួន។ ប៉ុន្តែ លក្ខខណ្ឌក្នុងការទទួលបានរបត់កំណើនសេដ្ឋកិច្ចថ្មី ស្ថិតនៅក្នុងភាពមិនប្រាកដប្រជានៅឡើយ ដោយសារតែចរិលក្ខណៈនៃកំណើនកាលពីទសវត្សកន្លងទៅ និងបញ្ហាពីបរិយាកាសខាងក្រៅ ។ ប្រទេសនេះមានសក្តានុពល ទទួលបានកំណើនសេដ្ឋកិច្ចថែមទៀត ហើយការវិភាគខាងដើមបានបញ្ជាក់ថាសក្តានុពលមានអ្វីខ្លះ។ វិបត្តិសេដ្ឋកិច្ចដែលកំពុងតែកើតមាននេះ គួរតែយកវាជាឱកាសមួយ ។ កម្ពុជាគប្បីចាត់ វិធានការច្បាស់លាស់ដើម្បីសំរេចបានសក្តានុពលនេះ។ យើងអាចដឹងជាមុនអំពីអ្វីដែលត្រូវធ្វើនោះទេ ប៉ុន្តែត្រូវតែមានការសិក្សាវិភាគជាបន្តអំពីឧបសគ្គដែលរារាំងកំណើនសេដ្ឋកិច្ច គោលនយោបាយថ្មីៗដែលកំពុងសាកល្បង ដោយបង្កើន អ្វីៗដែលជាជោគជ័យ និងរៀនសូត្រពីការបរាជ័យ។ ដំណើរការនេះនឹងត្រូវសង្កត់ធ្ងន់លើយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ច និងអភិបាលកិច្ចដែលមានការប្តេជ្ញាចិត្តច្បាស់។ លុះត្រាតែមានដំណើរការបែបនេះ ទើបប្រទេសកម្ពុជាអាចធានានិរន្តរ ភាពកំណើនសេដ្ឋកិច្ចឆ្ពោះទៅរកកំរិតថ្មីៗដែលរួមវិភាគទានដល់សុខុមាលភាព និងសមិទ្ធិផលសង្គមសំខាន់ៗមួយ ចំនួនផង។